ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងបរិស្ថាន

លេខ ១៧៧៨ សល.ជ.ណ.ប.ស្ក

# សេចក្តីប្រកាសព័ត៌មាន

## ការអនុម័តនិងដាក់ឱ្យប្រើប្រាស់យុទ្ធសាស្ត្រអភិវឌ្ឍន៍រយៈពេលវែង ប្រកបដោយអព្យាក្រឹតកាបូន (LTS4CN) របស់ប្រទេសកម្ពុជា

ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព និងក្រសួងបរិស្ថានមានកិត្តិយសសូមជម្រាបជូនសាធារណជន បណ្តាញសារព័ត៌មានជាតិ និងអន្តរជាតិ ដៃគូអភិវឌ្ឍន៍ អង្គការមិនមែនរដ្ឋាភិបាល ក្រសួង ស្ថាប័នជាតិ ស្ថានទូត និងអ្នកពាក់ព័ន្ធទាំងអស់ឱ្យបានជ្រាបថា កម្ពុជាបានដាក់ជូននូវយុទ្ធសាស្ត្រអភិវឌ្ឍន៍រយៈពេលវែងប្រកបដោយអព្យាក្រឹតកាបូន (LTS4CN) ទៅកាន់លេខាធិការដ្ឋានអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ (UNFCCC) **កាលពីថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២១។**

ការដាក់ជូនយុទ្ធសាស្ត្រនេះ គឺស្របតាមការប្តេជ្ញាចិត្តរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី** ថ្លែងក្នុងកិច្ចប្រជុំកំពូលស្តីពីមហិច្ឆតាអាកាសធាតុ របស់អង្គការសហប្រជាជាតិ ឆ្នាំ២០២០ ដើម្បីដាក់ឱ្យប្រើប្រាស់នៅដំណាច់ឆ្នាំ២០២១។ ការរៀបចំយុទ្ធសាស្ត្រនេះជាជំហានមួយដ៏សំខាន់ សម្រាប់កម្ពុជាក្នុងនាមជាប្រទេសគាំទ្រ នូវសកម្មភាពពហុភាគីក្នុងកិច្ចការងារប្រែប្រួលអាកាសធាតុ ដើម្បីបង្ហាញភាពជាដឹកនាំតាមរយៈការអនុវត្តជាក់ស្តែងនូវសកម្មភាពអាកាសធាតុ។

កម្ពុជាគឺជាប្រទេសមួយក្នុងចំណោមប្រទេសភាគីនៃអនុសញ្ញា UNFCCC ចំនួន ៤៩ ដែលបានដាក់ជូននូវយុទ្ធសាស្ត្រនេះទៅកាន់លេខាធិការដ្ឋានអនុសញ្ញា UNFCCC គិតត្រឹមពេលបច្ចុប្បន្ន ហើយជាប្រទេសអភិវឌ្ឍន៍តិចតួចទីពីរដែលបានដាក់ជូនយុទ្ធសាស្ត្រនេះដោយកំណត់គោលដៅច្បាស់លាស់សម្រាប់អព្យាក្រឹតភាពកាបូននៅឆ្នាំ ២០៥០។ ប្រការនេះបញ្ជាក់អំពីសក្ខីភាពមួយថ្មីទៀតលើការប្តេជ្ញាចិត្តដ៏រឹងមាំ សង្គតិភាព និងមានឆន្ទៈនយោបាយខ្ពស់ក្នុងការដោះស្រាយការប្រែប្រួលអាកាសធាតុ។

ទោះបីកម្ពុជា ចូលរួមចំណែកតិចតួចក្នុងការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ក្តី តែតាមរយៈយុទ្ធសាស្ត្រនេះកម្ពុជាបានបង្ហាញឆន្ទៈ និងជំហររបស់ខ្លួនក្នុងការចូលរួមជាមួយសហគមន៍អន្តរជាតិដើម្បីដោះស្រាយការប្រែប្រួលអាកាសធាតុ ផ្អែកតាមគោលការណ៍ **«ការទទួលខុសត្រូវរួម ប៉ុន្តែកម្រិតផ្សេងគ្នា ផ្អែកតាមសមត្ថភាពរៀងៗខ្លួន»**។

យុទ្ធសាស្ត្រនេះ មានគោលបំណងដើម្បីផ្តល់នូវផែនទីបង្ហាញផ្លូវ ផ្អែកលើការវិភាគគ្រប់ជ្រុងជ្រោយ និងសេណារីយ៉ូពាក់ព័ន្ធនឹងវិស័យសេដ្ឋកិច្ចសំខាន់ៗ រួមទាំងសកម្មភាពកាត់បន្ថយអាទិភាព ដើម្បីឈានឆ្ពោះទៅសម្រេចបានការអភិវឌ្ឍប្រកបដោយអព្យាក្រឹតកាបូននាពេលអនាគត។ យុទ្ធសាស្ត្រនេះរួមបញ្ចូលការវិភាគអំពីតុល្យភាពរវាងការកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់ ការរីកចម្រើនសេដ្ឋកិច្ច យុត្តិធម៌សង្គម និងភាពធន់នឹងអាកាសធាតុ។



អគារមរតកតេជោ ដីឡូលេខ503 ផ្លូវកៅស៊ូអមមាត់ទន្លេបាសាក់ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន ភ្នំពេញ ទូរស័ព្ទ: ០២៣ ២១៣ ៩០៨, ០២៣ ២២០ ៣៦៩ ទូរសារ: ០២៣ ២១២ ៥៤០

កម្ពុជាអាចសម្រេចបានអព្យាក្រឹតកាបូនត្រឹមឆ្នាំ២០៥០ តាមរយៈ ១) ការបន្តកិច្ចខិតខំប្រឹងប្រែងលើការអនុវត្តកម្មវិធីកាត់បន្ថយការបញ្ចេញឧស្ម័នដែលកើតឡើងដោយសារការបាត់បង់ និងការរេចរឹលព្រៃឈើ (REDD+) និងកំណែទម្រង់វិស័យព្រៃឈើរួមមាន ការអភិវឌ្ឍវិស័យព្រៃឈើប្រកបដោយនិរន្តរភាព ២) ការកាត់បន្ថយការបញ្ចេញឧស្ម័នពីវិស័យថាមពល និងការដឹកជញ្ជូន និងការលើកកម្ពស់ប្រសិទ្ធភាពថាមពល និង ៣) ការលើកកម្ពស់កសិកម្មបញ្ចេញកាបូនតិច ដំណើរការឧស្សាហកម្ម និងការគ្រប់គ្រងសំណល់។ ការអនុវត្តយុទ្ធសាស្ត្រ LTS4CN នឹងរួមចំណែកជំរុញកំណើនផលិតផលក្នុងស្រុកសរុប (GDP) ប្រចាំឆ្នាំបន្ថែមចំនួន ២,៨% នៅឆ្នាំ២០៥០ (ស្មើនឹង ៤,២ ប៊ីលានដុល្លារសហរដ្ឋអាមេរិក) ហើយអាចបង្កើតការងារបន្ថែមចំនួន ៤៤៩.០០០កន្លែង និងជំរុញការអនុវត្តសេដ្ឋកិច្ចបៃតង និងការអភិវឌ្ឍបញ្ចេញកាបូនតិច។

ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព និងក្រសួងបរិស្ថានសូមថ្លែងអំណរគុណ ចំពោះក្រសួង ស្ថាប័ន និងដៃគូនានា រួមមាន៖ កម្មវិធីសម្ព័ន្ធភាពប្រែប្រួលអាកាសធាតុកម្ពុជា (ដោយមានការគាំទ្រថវិកាពីសហភាពអឺរ៉ុប ប្រទេសស៊ុយអែត និងកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ) ចក្រភពអង់គ្លេស ធនាគារពិភពលោក អង្គការស្បៀងអាហារ និងកសិកម្មសហប្រជាជាតិ វិទ្យាស្ថានអភិវឌ្ឍន៍បៃតងសកល និងទីភ្នាក់ងារបារាំងដើម្បីអភិវឌ្ឍន៍ ដែលបានជួយគាំទ្រ និង សហការក្នុងដំណើរការរៀបចំយុទ្ធសាស្ត្រនេះ។ យើងសង្ឃឹមយ៉ាងមុតមាំថាយើងនឹងអាចបង្កើត និងអនុវត្តក្នុងភាពជាដៃគូប្រកបដោយប្រសិទ្ធភាព ដើម្បីគាំទ្រដល់ការអនុវត្តយុទ្ធសាស្ត្រ LTS4CN។

ព័ត៌មានលម្អិតអំពីយុទ្ធសាស្ត្រអភិវឌ្ឍន៍រយៈពេលវែងប្រកបដោយអព្យាក្រឹតកាបូនអាចទាញយកបានក្នុងតំណភ្ជាប់៖ https://unfccc.int/sites/default/files/resource/KHM_LTS_Dec2021.pdf

ថ្ងៃសុក្រ ១២ រោច ខែ មិគសិរ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ២០២១

***ព័ត៌មានបន្ថែម សូមទាក់ទង :***


នាយកដ្ឋានប្រែប្រួលអាកាស
ទូរស័ព្ទ៖ (855) 78 996 479
អ៊ីម៉ែល៖ maohakccd.se@gmail.com
គេហទំព័រ៖ https://ncsd.moe.gov.kh